ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២ សសរ

# សេចក្ដីសម្រេច
# ស្ដីពីការកែសម្រួលរបៀបរបបការងារ និង ការបែងចែកភារកិច្ច
# របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្ដីសម្រេចលេខ ៣៧សសរ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាល ស្ដីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** កែសម្រួល និងកំណត់ភារកិច្ចជូន ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ដូចមានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២ :** ឧបនាយករដ្ឋមន្ត្រី ៖

១- ឯកឧត្តម **ហោ ណាំហុង** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកផ្ដល់យោបល់ជូននាយករដ្ឋមន្ត្រី អំពីក្របខ័ណ្ឌគោលនយោបាយក្រៅប្រទេស និងការងារពិសេសផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

២- ឯកឧត្តម **ប៊ិន ឈិន** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ ដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រី ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យ និងសម្រេចលើការងាររបស់ «ច្រកចេញ-ចូលតែមួយ» នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើកលែងតែការងារដែលមានវេទយិតភាពខ្ពស់ ដែលតម្រូវឱ្យសុំការណែនាំ ឬការសម្រេចពីនាយករដ្ឋមន្ត្រី និងទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី

ក្នុងការពិនិត្យ និងសម្រេចលើសំណើសុំកូន និងការសុំលាសញ្ជាតិ ដឹកនាំផ្ទាល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជួយនាយករដ្ឋមន្ត្រីលើការងារបង្ការ ទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ ។

**ប្រការ ៣ :** នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រីដែលត្រូវប្រជុំពិគ្រោះការងារតាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីស្តីទី ។

**ប្រការ ៤ :** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកអនុវត្តការងារ ឬបេសកកម្មផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូនស្របតាមមាត្រា១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

**ប្រការ ៥ :** ឧបនាយករដ្ឋមន្ត្រី ១ រូបៗ មានទីប្រឹក្សា ៤ រូប ក្នុងនោះ ២ រូប មានឋានៈស្មើ រដ្ឋលេខាធិការ ២ រូប មានឋានៈស្មើ អនុរដ្ឋលេខាធិការ និងជំនួយការ ៥ រូប ក្នុងនោះ ១ រូប មានឋានៈស្មើ អគ្គនាយក ២ រូប មានឋានៈស្មើ អគ្គនាយករង និង ២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ ៦ :** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ៖

១- ឯកឧត្តម **សេរី កុសល** : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ១ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ។

២- ឯកឧត្តម **លី ធុជ** : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ២ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ប្រធានគណៈកម្មាធិការជាតិ ESCAP និងជាអនុប្រធានទី ២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ។

៣- ឯកឧត្តម **ជិន ម៉ុនស៊ាន** : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៤- ឯកឧត្តម **មិន ឃិន** : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានគណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ និងជួយនាយករដ្ឋមន្ត្រីអំពីការងារវប្បធម៌ ។

៥- ឯកឧត្តម **អ៊ឹម សួស្តី** : ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

**ប្រការ ៧ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ ៨ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ១ រូបៗ មានជំនួយការ ៥ រូប ក្នុងនោះ ២ រូបមានឋានៈស្មើ អគ្គនាយក ១ រូប មានឋានៈស្មើ អគ្គនាយករង និង ២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ ៩ :** នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ប្រធានគ្រប់ស្ថាប័នត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល ៖</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ដូចប្រការ ២ , ៦ និង ៩
-ឯកសារ-កាលប្បវត្តិ